# ADB

# គោលនយោបាយស្តីពី
# ជនអន្តោប្រាម

ធនាគារអភិវឌ្ឍន៍អាស៊ី

ADB

# គោលនយោបាយស្តីពី
# ជនអន្តោប្រាម

ធនាគារអភិវឌ្ឍន៍អាស៊ី
ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន
១៩៩៩

បោះពុម្ពដោយធនាគារអភិវឌ្ឍន៍អាស៊ី ១៩៩៩

ធនាគារអភិវឌ្ឍន៍អាស៊ីលើកទឹកចិត្តឱ្យមានការប្រើប្រាស់សៀវភៅនេះ ដោយផ្ដល់កិត្តិយសសមស្របដល់ធនាគារ ។ សូមសាកសួររកសៀវភៅនេះ ទៅការិយាល័យទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ប្រអប់សំបុត្រលេខ ៧៨៩, ០៩៨០ ម៉ានីល ហ្វីលីពីន ។

រក្សាសិទ្ធិ

ISBN: 971-561-175-3

ស្តុកលេខ : ០៦០២៩

# អក្សរកាត់

ADB Asian Development Bank

ធនាគារអភិវឌ្ឍន៍អាស៊ី

ILO International Labour Organisation

អង្គការពលកម្មអន្តរជាតិ

ISA initial social assessment

ការវាយតំលៃបឋមផ្នែកសង្គម

OESD Office of Environment and Social Development

ការិយាល័យបរិស្ថាន និងអភិវឌ្ឍន៍សង្គម

PPTA project preparatory technical assistance

ជំនួយការបច្ចេកទេសរៀបចំគំរោងការ

RRP Reprot and Recommendation of the President

របាយការណ៍ និងអនុសាសន៍របស់ប្រធាន

UNCED United Nations Conference on Environment and Development

សន្និសីទអង្គការសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍

UNDP United Nations Development Programme

កម្មវិធីអង្គការសហប្រជាជាតិសំរាប់ការអភិវឌ្ឍន៍

## ADB DISCLAIMER FOR TRANSLATED DOCUMENTS

This document has been translated from English in order to reach a wider audience. However, English is the official language of the Asian Development Bank and the English original of this document is the only authentic (that is, official and authoritative) text. Any citations must refer to the English original of this document.

## **សេចក្តីអះអាងរបស់ ADB ចំពោះឯកសារបកប្រែនេះ**

ឯកសារនេះត្រូវបានបកប្រែចេញពីភាសាអង់គ្លេស ដើម្បីផ្សព្វផ្សាយដល់សវនកៈឱ្យកាន់តែទូលំទូលាយ ។ ប៉ុន្តែភាសាអង់គ្លេស គឺជាភាសាផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង ឯកសារដើមជាភាសាអង់គ្លេសនៃឯកសារនេះ គឺជាអត្ថបទត្រឹមត្រូវតែមួយគត់ (មានន័យថា ជាឯកសារផ្លូវការនិងអាចយកជាការបាន)។ ការស្រង់ចេញនានាត្រូវតែយោងទៅលើឯកសារដើមជាភាសាអង់គ្លេស ។

# មាតិកា


**ទំព័រ**

**អក្សរកាត់** iii

**សេចក្តីផ្តើម** 1

**និយមន័យនៃពាក្យ ជនអន្តោប្រាណ** 5

**ជនអន្តោប្រាណ និងការអភិវឌ្ឍន៍** 9

គោលដៅ និងវត្ថុបំណងនានានៃការអភិវឌ្ឍន៍ 10

វប្បធម៌ និងការអភិវឌ្ឍន៍ 11

**ច្បាប់ និងអនុសញ្ញានានាដែលពាក់ព័ន្ធចលជនអន្តោប្រាណ** 13

ច្បាប់ជាតិ និងទំលាប់ប្រតិបត្តិ 13

អនុសញ្ញា និងសេចក្តីថ្លែងការណ៍អន្តរជាតិ 14

**វត្ថុបំណងនៃគោលនយោបាយ ដំណើរការ និងដំណោះស្រាយក្នុងរង្វង់ ADB** 17

វត្ថុបំណងនៃគោលនយោបាយ 17

ដំណើរការកិច្ចប្រតិបត្តិការ 18

ដំណោះស្រាយប្រតិបត្តិការ 21

**ស្ថាប័នពាក់ព័ន្ធ** 23

**គោលនយោបាយស្តីពីជនអន្តោប្រាណ** 25

គោលនយោបាយស្តីពីជនអន្តោប្រាណក្នុងកិច្ចប្រតិបត្តិការ ADB 25

**ឧបសម្ព័ន្ធ** 27

# សេចក្តីផ្តើម

ជនអន្តោគ្រាម [1] ត្រូវបានគេចាត់ទុកថា ជាក្រុមមនុស្សក្នុងសង្គមដ៏ធំមួយដែលងាយរងគ្រោះបំផុត ។ ក្រៅពីមានភាពខុសគ្នាដ៏ធំធេងខាងផ្នែកវប្បធម៌ អត្តសញ្ញាណ ប្រព័ន្ធសេដ្ឋកិច្ច និងស្ថាប័នសង្គម ជនអន្តោគ្រាមជាទូទៅមានភាពចាញ់ប្រៀប បើគិតពីសន្ទស្សន៍សង្គម ស្ថានភាពសេដ្ឋកិច្ច និងគុណភាពផ្នែកជីវភាព ។ ជាធម្មតា ជនអន្តោគ្រាមនៅតែគ្មានលទ្ធភាពចូលរួមដោយស្មើភាពក្នុងដំនើរការអភិវឌ្ឍន៍ និងគ្មានលទ្ធភាពទទួលផលកំរៃពីការអភិវឌ្ឍន៍ដោយស្មើភាពឡើយ ហើយជារឿយៗទៀត ពួកគេពុំអាចតំណាងគ្រប់គ្រាន់នៅក្នុងដំណើរការផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយជាតិ ដែលកំណត់នូវការអភិវឌ្ឍន៍ ។ ថ្វីត្បិតតែជនអន្តោគ្រាមជាផ្នែកមួយតូចនៃប្រជាជនក្នុងតំបន់របស់ ADB ក៏ដោយ ក៏ជនទាំងនោះ និងភាពងាយរងគ្រោះជាយថាហេតុនៃជនទាំងនោះ ត្រូវតែចាត់ទុកថាជាមុខព្រួញដ៏សំខាន់ នៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍន៍ និងអន្តរាគមន៍របស់ ADB ។

គេមិនគួរ ហើយក៏មិនអាចដាក់ឱ្យជនអន្តោគ្រាមនៅឯកោ ឬក៏ផាត់ពួកគេចេញពីការអភិវឌ្ឍន៍បានឡើយ ។ ក៏ដូចជាប្រជាជនដែលមានឧត្តមភាព ឬប្រជាជនភាគច្រើន ពោលគឺក្រុមមនុស្សនៅក្នុងប្រទេសដែលមានអំណាចខ្លាំងក្លាខាងផ្នែកនយោបាយ សេដ្ឋកិច្ច និង

---

[1] ពាក្យថា "ជនអន្តោគ្រាម" ដែលត្រូវបានយកមកប្រើប្រាស់ក្នុងទីនេះក្រសោបបញ្ញត្តិទូទៅដែលពិបាកនឹងបញ្ជាក់ច្បាស់នូវន័យស័ព្ទតែមួយ ។ ន័យស័ព្ទផ្សេងទៀតទាក់ទងទៅនឹងបញ្ញត្តិជនអន្តោគ្រាមដែលបានបកស្រាយក្នុងគោលនយោបាយ ADB មានរួមបញ្ចូលទាំង "វប្បធម៌ជនជាតិភាគតិច" "ជនជាតិភាគតិច" "សហគមន៍វប្បធម៌ជនអន្តោគ្រាម" "កុលសម្ព័ន្ធ" "ជនជាតិដើម" និង "អ្នកស្រុកដើម" ។ ការទទួលយក ឬការពេញចិត្តន័យស័ព្ទ និងនិយមន័យមានការប្រែប្រួលទៅតាមប្រទេស និងតាមមុខវិជ្ជានីមួយៗ និងទៅតាមការប្រើប្រាស់របស់ក្រុមនានាដែលពាក់ព័ន្ធ ។ ពាក្យថា "ជនន្តោគ្រាម" គឺជាន័យស័ព្ទត្រូវបានប្រើប្រាស់ក្នុងឯកសារអង្គការសហប្រជាជាតិ និងត្រូវបានប្រើប្រាស់ដាច់តែឯងដោយ ADB សំរាប់បំរើការងាយស្រួលរបស់ខ្លួន ។

វប្បធម៌នោះ ជនអន្ដោគ្រាមក៏មានសេចក្ដីប្រាថ្នាចង់បានការអភិវឌ្ឍន៍ដូចគេឯងផងដែរ ។ ក៏ប៉ុន្ដែ ជនអន្ដោគ្រាមទាំងនោះអាចមិនទាន់បានទទួលផលកំរៃពីកម្មវិធីអភិវឌ្ឍន៍នានាដែលរៀបចំឡើង សំដៅឆ្លើយតបទៅនឹងតំរូវការ និងសេចក្ដីប៉ងប្រាថ្នារបស់ប្រជាជនដែលមានឧត្ដមភាពលើសលុប ឬក្រុមមនុស្សភាគច្រើន ហើយជនអន្ដោគ្រាមប្រហែលជានៅពុំទាន់មានឱកាសក្នុងការចូលរួមធ្វើផែនការអភិវឌ្ឍន៍ណាមួយឡើយ ។ មានកំណើននូវក្ដីព្រួយបារម្ភក្នុងសហគមន៍អភិវឌ្ឍន៍អន្ដរជាតិ ដែលថាជនអន្ដោគ្រាមពុំត្រូវបានគេលៃលកឱកាសដើម្បីចូលរួម និងទទួលផលកំរៃ ក្នុងការអភិវឌ្ឍន៍ ដោយស្មើភាពជាមួយក្រុមមនុស្សក្នុងសង្គមដទៃទៀត ហើយពុំមានតួនាទី និងពុំអាចចូលរួមក្នុងការរៀបចំកម្មវិធីអភិវឌ្ឍន៍ ដែលមានផលប៉ះពាល់ទៅលើពួកគេ ។

បទបញ្ញត្តិ និងគោលនយោបាយនានារបស់ប្រទេសសមាជិក ADB ភាគច្រើនទទួលស្គាល់ថា ជនអន្ដោគ្រាមទាំងនោះជាប្រជាពលរដ្ឋផងខ្លួន ។ ប៉ុន្ដែ តាមការជាក់ស្ដែង ជារឿយៗពួកគេនៅតែមានប្រៀបចាញ់ ក្នុងការធ្វើអន្ដរកម្មជាមួយនឹងប្រជាជនដែលមានឧត្ដមភាពលើសលប់ដដែល ជាពិសេសទៅលើអ្វីដែលទាក់ទងនឹងការអភិវឌ្ឍន៍ ។ ក្រៅពីការដែលពួកគេមិនបានទទួលផលកំរៃពីការអភិវឌ្ឍន៍ និងមិនបានចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍន៍ ពួកជនអន្ដោគ្រាមទាំងនោះអាចទទួលនូវផលវិបាកអាក្រក់ថែមទៀត ដោយសារតែពួកគេបាត់បង់សិទ្ធិកាន់កាប់ដីកេរ្ដិ៍ដូនតា ពុំមានលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ និងប្រភពចំនួលផ្សេងទៀតពីដីធ្លី, បាត់បង់វប្បធម៌ រចនាសម្ព័ន្ធសង្គម និងស្ថាប័ន, បាត់បង់ចំណេះដឹងប្រពៃណីរបស់ខ្លួន, បាត់បង់ការទទួលស្គាល់ពួកគេថាជាជនអន្ដោគ្រាម និងពុំមានឱកាសសំរាប់ការចូលរួមដ៏មានប្រសិទ្ធិភាព ក្នុងដំណើការនយោបាយ និងសេដ្ឋកិច្ចជាតិ ។ ក្នុងករណីភាគច្រើន កង្វះខាតការចូលរួមក្នុងការអភិវឌ្ឍន៍ បូកផ្សំនឹងការបាត់បង់សិទ្ធិក្នុងការប្រើប្រាស់ដីធ្លី និងធនធានទាំងឡាយរបស់ជនអន្ដោគ្រាមទាំងនោះ បានរុញច្រានពួកគេឱ្យកាន់តែឆ្ងាយពីសង្គម ។ ក្នុងករណីជ្រុលហួសហេតុខ្លះ ពួកជនអន្ដោគ្រាមបានទទួលរងការឈឺចាប់ដោយការកៀបសង្កត់ផ្លូវកាយ ។ ក្នុងករណីខ្លះទៀត វប្បធម៌ពួកគេត្រូវបានបែកបាក់ ឬទទួលការបាត់បង់តែម្ដង ។

ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ADB ទទួលស្គាល់ និងគោរពអធិប្បតេយ្យភាពនៃប្រទេសសមាជិក រួមទាំងច្បាប់នៃប្រទេសនីមួយៗ ព្រមទាំងគោលនយោបាយនៃប្រទេសទាំងនោះ ដែលទាក់ទងនឹងជនអន្តោគ្រាមផងដែរ ។ ក៏ប៉ុន្តែនៅពេលជាមួយគ្នានេះ ADB ក៏ទទួលស្គាល់ការទទួលខុសត្រូវទៅលើការធានាឱ្យមានឱកាសស្មើគ្នា សំរាប់ជនអន្តោគ្រាម ហើយ កិច្ចប្រតិបត្តិការ និងជំនួយរបស់ខ្លួននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក មិននាំមកនូវផលប៉ះពាល់ជាអវិជ្ជមានអ្វីទៅលើសុខមាលភាព និងផលប្រយោជន៍ជនអន្តោគ្រាមទាំងនោះឡើយ ។ ប្រសិនបើអន្តរាគមន៍ណាមួយរបស់ ADB ប្រាកដជាមានផលប៉ះពាល់ជាអវិជ្ជមានទៅលើជនអន្តោគ្រាម នោះវិធានការដ៏ពេញលេញនឹងត្រូវចាត់ឡើង សំរាប់កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន ឬក៏ធ្វើឱ្យច្បាស់ថា ផែនការសងជំងឺចិត្តមួយត្រូវរៀបចំ និងអនុវត្ត សំរាប់ជនដែលទទួលផលប៉ះពាល់ពីគំរោង ។

គោលនយោបាយរបស់ ADB ចំពោះជនអន្តោគ្រាមកំណត់វិធីដោះស្រាយទាំងឡាយ ដែលទទួលស្គាល់នូវស្ថានភាពជនអន្តោគ្រាម និងកំណត់វិធានការទាំងឡាយ ដែលសំដៅបំពេញតំរូវការ និងសេចក្តីប្រាថ្នាក្នុងការអភិវឌ្ឍន៍របស់ជនអន្តោគ្រាម ។ គោលនយោបាយនេះសង្កត់ធ្ងន់លើការចូលរួមរបស់ជនអន្តោគ្រាមក្នុងការអភិវឌ្ឍន៍ និងការកាត់បន្ថយផលប៉ះពាល់ដែលគេមិនចង់បាននៃការអភិវឌ្ឍន៍ ។ គោលនយោបាយនេះផ្តល់និយមន័យមួយរបស់ជនអន្តោគ្រាម សំរាប់ប្រើក្នុងកិច្ចប្រតិបត្តិការនានារបស់ ADB ។ គោលនយោបាយនេះក៏ផ្តោតការយកចិត្តទុកដាក់ផងដែរលើច្បាប់ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធទាំងឡាយ ក៏ដូចជាទំលាប់ប្រតិបត្តិរបស់បណ្តាស្ថាប័នប្រហាក់ប្រហែលគ្នា ។ ជាទីបញ្ចប់ គោលនយោបាយនេះបង្ហាញពីសំណុំនៃវត្ថុបំណង និងវិធីដោះស្រាយប្រតិបត្តិការ ក៏ដូចជានីតិវិធីនានា ហើយពិចារណាលើការជំពាក់ទាក់ទងផ្នែកស្ថាប័ននៃគោលនយោបាយផ្លូវការរបស់ ADB ដែលតំរង់ឆ្ពោះទៅរកជនអន្តោគ្រាម ។

# និយមន័យពាក្យ ជនអន្តោប្រវេសន៍

ការបង្កើតនិយមន័យ ឬអត្តសញ្ញាណកម្មតែមួយ និងជាក់លាក់ សំរាប់ពាក្យជនអន្តោអន្តោប្រវេសន៍ អាចជួបប្រទះនឹងការលំបាក ។ ក្នុងរង្វង់តំបន់អាស៊ីប៉ាស៊ីភិច សហគមន៍ជនអន្តោប្រវេសន៍នីមួយៗបង្ហាញនូវភាពខុសប្លែកគ្នាដ៏ធំសំបើមខាងវប្បធម៌ ប្រវត្តិសាស្ត្រ និងស្ថានភាពបច្ចុប្បន្នរបស់ពួកគេ ។ ពីប្រទេសមួយទៅប្រទេសមួយ ទំនាក់ទំនងរវាងជនអន្តោប្រវេសន៍ និងសង្គមជនដែលមានឧត្តមភាពលើសលុប ឬក្រុមជនជាតិភាគច្រើន មានភាពប្លែកៗពីគ្នា ។

ក្នុងទស្សនៈនៃការបង្កើតនិយមន័យរបស់ពាក្យជនអន្តោប្រវេសន៍ សំរាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការរបស់ ADB ចាំបាច់ត្រូវពិចារណាលើទិដ្ឋភាពមួយចំនួន ។ ជាដំបូង គេត្រូវកំណត់នូវនិយមន័យនៃពាក្យជនអន្តោប្រវេសន៍ ដោយឈរលើមូលដ្ឋាននៃលក្ខណៈទាំងឡាយដែលគេបានបង្ហាញ ។ លក្ខណៈសំខាន់ពីរគឺ :

- មានដើមកំណើតចេញពីក្រុមប្រជាជនដែលរស់នៅលើទឹកដីកំណត់ណាមួយ ដែលភាគច្រើនតាំងមុនការបង្កើតរដ្ឋ ឬដែនដីបច្ចុប្បន្ន និងមុនការកំណត់ព្រំដែនបច្ចុប្បន្ន ។
- មានការរក្សាទុកនូវអត្តសញ្ញាណវប្បធម៌ និងសង្គម ព្រមទាំងស្ថាប័នសង្គម សេដ្ឋកិច្ច និងនយោបាយ ដោយឡែកពីសង្គម និងវប្បធម៌របស់ប្រជាជនដែលមានឧត្តមភាពលើសលុប ឬប្រជាជនភាគច្រើន ។ ក្នុងករណីខ្លះ នាសតវត្សថ្មីនេះ ក្រុមកុលសម្ព័ន្ធ ឬវប្បធម៌ជនជាតិភាគតិចបានផ្លាស់ទីទៅកាន់កន្លែងមួយ ដែលក្រុមកុលសម្ព័ន្ធ ឬវប្បធម៌ជនជាតិភាគតិចទាំងនោះមិនមែនជាអន្តោប្រវេសន៍ ក៏ប៉ុន្តែបាននៅមានអត្ថិភាព និងបន្តរក្សាអត្តសញ្ញាណសង្គម និងវប្បធម៌ ក៏ដូចជាស្ថាប័នពាក់ព័ន្ធច្បាស់លាស់ ហើយដាច់ដោយឡែកពីគេ ។ ក្នុងករណីបែបនេះ លក្ខណៈទី ២ ដែលបានបង្ហាញជូនខាងលើមានទម្ងន់ធ្ងន់ជាង ។

លក្ខណៈដែលត្រូវបានគេតាក់តែងបន្ថែម សំរាប់ជនអន្តោគ្រាមរួមមាន :

- ការធ្វើស្វ័យអត្តសញ្ញាណកម្ម និងការកំណត់អត្តសញ្ញាណកម្មពីអ្នកដទៃ ថាជាផ្នែកនៃក្រុមវប្បធម៌អន្តោគ្រាមដោយឡែកណាមួយ និងការបង្ហាញពីបំណងក្នុងការរក្សាការពារអត្តសញ្ញាណវប្បធម៌នោះ ។
- ភាពខុសប្លែកនៃអត្តសញ្ញាណភាសាពីសង្គមមនុស្សដែលមានឧត្តមភាពលើសលុប ។
- ប្រពៃណី និងស្ថាប័នសង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយ មានភាពខុសប្លែកពីវប្បធម៌ក្រុមដែលមានឧត្តមភាពលើសលុប ។
- ប្រព័ន្ធសេដ្ឋកិច្ចតំរង់ទិស ឆ្ពោះទៅរកប្រព័ន្ធផលិតកម្មប្រពៃណី ខ្លាំងជាងប្រព័ន្ធរបស់ក្រុមដែលមានឧត្តមភាពលើសលុប ។
- ចំណង និងការផ្សារភ្ជាប់ដោយឡែកទៅនឹងស្រុកភូមិជាប្រពៃណី ទឹកដីដូនតា និងធនធានធម្មជាតិនៅក្នុងស្រុកភូមិ និងទឹកដីទាំងនោះ ។

ជនអន្តោគ្រាម ក៏ត្រូវបានគេកំណត់សំគាល់ផងដែរ ដោយយោងទៅតាមរបៀបរស់នៅរបស់ពួកគេ ។ ក្នុងករណីជាច្រើន ជនអន្តោគ្រាមរស់នៅក្នុងសហគមន៍ ឬវប្បធម៌ ឬជាតិសាសន៍ដាច់ដោយឡែក ។ ជាញឹកញាប់ សហគមន៍ និងជនអន្តោគ្រាមបែបនេះរស់នៅក្នុងតំបន់ឆ្ងាយពីទីប្រជុំជន និងទីក្រុង និងតែងតែបំពេញមុខងារនៅក្រៅប្រព័ន្ធនយោបាយសង្គម វប្បធម៌ និងសេដ្ឋកិច្ច របស់សង្គមក្រុមដែលមានឧត្តមភាពលើសលុប ឬក្រុមជនជាតិភាគច្រើន ។ នៅក្នុងពេលជាមួយគ្នានេះ ទោះបីជាយ៉ាងណាក៏ដោយ ក៏គេអាចពើបប្រទះសហគមន៍ជនអន្តោគ្រាមនៅតំបន់ជាយក្រុង ដែលបានធ្វើការផ្លាស់ទីលំនៅ ប៉ុន្តែនៅរក្សាភាពខុសប្លែកពីក្រុមមនុស្សភាគច្រើន ។ សហគមន៍ជនអន្តោគ្រាមនៅក្នុងប្រទេសណាមួយអាចបង្ហាញឱ្យឃើញនូវកំរិតផ្សេងៗគ្នានៃការរលាយចូល និងការធ្វើសមាហរណកម្មទៅក្នុងសង្គមនៃក្រុមមនុស្សមានឧត្តមភាពលើសលប់ ឬក្រុមមនុស្សភាគច្រើន ។

និយមន័យការងារដែលត្រូវបានប្រើប្រាស់នៅក្នុងកិច្ចប្រតិបត្តិការរបស់ ADB ដែលនិយាយពីជនអន្តោគ្រាមគឺ :

*ជនអន្តោប្រាណគឺជាក្រុមមនុស្ស ដែលមានអត្តសញ្ញាណសង្គម ឬវប្បធម៌ ដោយឡែកពីសង្គមអ្នកមានឧត្តមភាព ឬសង្គមមនុស្សភាគច្រើន ដែលធ្វើអោយពួកគេងាយរងគ្រោះដោយមានភាពចាញ់ប្រៀប នៅក្នុងដំនើរការអភិវឌ្ឍន៍ ។*

ក្នុងអន្តរាគមន៍អភិវឌ្ឍន៍ជាក់ស្តែងដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី ច្បាប់ជាតិរបស់ប្រទេសណាមួយដែលមានការធ្វើអន្តរាគមន៍អភិវឌ្ឍន៍ រួមចំណែកជាមូលដ្ឋាន ក្នុងការឱ្យនិយមន័យជនអន្តោប្រាណ ។ ច្បាប់ទាំងនេះរួមមានច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់នីតិបញ្ញត្តិ និងច្បាប់ទំនៀមទំលាប់ ព្រមទាំងច្បាប់អន្តរជាតិ ដោយរួមទាំងអនុសញ្ញាអន្តរជាតិទាំងឡាយ ដែលប្រទេសនោះជាសមាជិក ។ ជាការចាំបាច់ណាស់ដែលថា ត្រូវតែគិតគូរពិចារណាលើលក្ខណៈពិសេសដោយឡែកនានារបស់ប្រទេសនោះផងដែរ ។

ការកំណត់ប្រតិបត្តិនៃអត្តសញ្ញាណកម្មណាមួយមួយសំរាប់ជនអន្តោប្រាណ ត្រូវផ្អែកលើការទាមទារនៃច្បាប់ជាតិដែលអនុវត្ត និងភាពអាចប្រើប្រាស់បាននៃនិយមន័យ និងលក្ខណៈនានាដែលបានអធិប្បាយខាងលើ ។ ការប្រើប្រាស់និយមន័យជនអន្តោប្រាណណាមួយ ត្រូវតែអាចឱ្យគេបង្ហាញនូវភាពខុសគ្នារវាងជនអន្តោប្រាណ និងជនភាគតិចផ្សេងទៀត ដែលមានជាតិសាសន៍ និងវប្បធម៌ដ៏ទៃទៀត ហើយដែលស្ថានភាពអន្តោប្រាណមិនមែនជាបញ្ហាចោទ ។ កិច្ចការពារទូទៅនៃ ក្រុមងាយរងគ្រោះនានាគឺជាបញ្ហាមួយ ដែលមានលើកយកមកពិចារណា នៅក្នុងគោលនយោបាយ និងការអនុវត្តន៍ផ្សេងទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

ការធ្វើអត្តសញ្ញាណកម្មករណីជាក់លាក់លើជនអន្តោប្រាណ ដែលទទួលរងផលប៉ះពាល់ដោយសារប្រតិបត្តិការ និងដំណោះស្រាយរបស់ ADB ដើម្បីដោះស្រាយបញ្ហាកង្វល់ពិតប្រាកដរបស់ជនអន្តោប្រាណ នឹងត្រូវលើកយកមកពិចារណានៅក្នុងដំណើរការវាយតំលៃសង្គមបឋម និងការរៀបចំផែនការជនអន្តោប្រាណ (សូមមើលទំព័រ ១៧-២៣ និងឧបសម្ព័ន្ធ) ។

# ជនអន្តោគ្រាម និងការអភិវឌ្ឍន៍

នៅពេលដែលការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចបានកើតឡើង គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ជាច្រើនបានត្រូវពង្រីកយ៉ាងឆ្ងាយចូលទៅក្នុងតំបន់ចុងកាត់មាត់ញក ដែលជារឿយៗគេតែងតែចាត់ទុកជាជាតិទឹកដីប្រពៃណីរបស់ជនអន្តោគ្រាម ។ ទឹកដីទាំងនោះតែងតែផ្តល់ធនធាននានាដូចជា ព្រៃឈើ រ៉ែ និងសក្តានុពលវារីថាមពល ។ ជាមួយគ្នានេះ ផ្លូវថ្នល់ បណ្តាញបញ្ជូនថាមពល និងគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ក៏ត្រូវរីកដុះដាលចូលទៅកាន់ទឹកដីប្រពៃណីរបស់ជនអន្តោគ្រាម ។ ព្រមគ្នាជាមួយនឹងការអភិវឌ្ឍន៍រូបវ័ន្ត និងសេដ្ឋកិច្ច ប្រជាជនដែលមានឧត្តមភាពលើសលុប និងក្រុមជនជាតិភាគច្រើន ក៏បានចូលទៅតាំងទីលំនៅក្នុងទឹកដីប្រពៃណីជនអន្តោគ្រាម ដោយនាំទៅជាមួយនូវវប្បធម៌ពួកគេផងដែរ ។

កិច្ចការពារជនអន្តោគ្រាមពីការអភិវឌ្ឍន៍ និងពីការរក្សាពួកគេឱ្យនៅក្នុងស្ថានភាពដដែល មិនមែនជាវត្ថុបំណងនៃការអភិវឌ្ឍន៍នោះទេ ។ ក្នុងពេលជាមួយគ្នានេះ ជាញឹកញាប់ ផលប្រយោជន៍របស់ជនអន្តោគ្រាមមានភាពខុសប្លែកពីផលប្រយោជន៍របស់ក្រុមប្រជាជនដែលមានឧត្តមភាពលើសលុប ហើយគោលនយោបាយ និងវិធីអភិវឌ្ឍន៍ ដែលតំរង់ឆ្ពោះទៅរកផលប្រយោជន៍របស់សហគមន៍ដែលមានឧត្តមភាពលើសលុប មានទំនាស់នឹងផលប្រយោជន៍របស់ជនអន្តោគ្រាម ។ អ្វីដែលជាផលប្រយោជន៍ជាតិទាំងមូលអាចមិនមែនជាផលប្រយោជន៍ផ្ទាល់ដោយឡែករបស់ជនអន្តោគ្រាម ហើយការអភិវឌ្ឍន៍ដែលកើតចេញពីការផ្តួចផ្តើមរបស់សហគមន៍ដែលមានឧត្តមភាពលើសលុប អាចចេញជារូបរាងដែលមិនស្របទៅនឹងផលប្រយោជន៍ និងកង្វល់របស់ជនអន្តោគ្រាមផងដែរ ។

ការអភិវឌ្ឍន៍ តាមការប្រាថ្នាស្វែងរកជារឿយៗនោះ គឺមានបំណងសំរេចឱ្យបាននូវគោលបំណងរបស់ជាតិ និងសំរេចផលប្រយោជន៍របស់សង្គមនៃជនដែលមានឧត្តមភាពលើសលុប ។ ជាទូទៅ ការកាត់បន្ថយភាពក្រីក្រ និងការកែលំអគុណភាពជីវភាពប្រជាជន

គឺជាវត្ថុបំណងបឋមរបស់ការអភិវឌ្ឍន៍ ។ ក៏ប៉ុន្តែ ជួនកាលការកាត់បន្ថយភាពក្រីក្រ និងការកែលំអគុណភាពជីវភាព តាមរយៈការអភិវឌ្ឍន៍ ពុំបានប្រព្រឹត្តទៅឱ្យបានស្មើគ្នាសំរាប់គ្រប់ស្រទាប់នៃសង្គម ឬការកែលំអនេះត្រូវបានទទួលដោយប្រជាជនគ្រប់ស្រទាប់នៃសង្គមនោះឡើយ ។ លើសពីនេះទៀត នៅក្នុងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលតំរង់ទិសទៅឡើក្រុមជនដែលមានឧត្តមភាព ជនអន្តោប្រវេសន៍អាចរងនូវទម្ងន់ដ៏ធ្ងន់ធ្ងរនៃផលប៉ះពាល់ជាអវិជ្ជមានផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលគំរោងអភិវឌ្ឍន៍ទាំងនោះអាចនាំមកដោយមិនបានសំរេចនូវផលប្រយោជន៍សមស្របនោះឡើយ ។

## គោលដៅ និងវត្ថុបំណងនានានៃការអភិវឌ្ឍន៍

សង្គមជនដែលមានឧត្តមភាពលើសលុប និងសហគមន៍អន្តោប្រវេសន៍ អាចមានទស្សនៈផ្សេងៗគ្នា ស្តីពីគោលដៅ និងវត្ថុបំណងទូទៅ ដែលការអភិវឌ្ឍន៍ត្រូវសំរេច ។ តាមទស្សនៈក្រុមជនដែលមានឧត្តមភាពលើសលុប ជារឿយៗការអភិវឌ្ឍន៍ត្រូវបានគេវាស់វែងលើការលូតលាស់ផ្នែកសេដ្ឋកិច្ច ឬផលកំរៃ និងការកែលំអ នៅក្នុងរង្វង់នៃនិយមន័យនៃពាក្យគុណភាពជីវិត ដែលពួកគេយល់ឃើញ ហើយជាញឹកញាប់តែងសង្កត់ធ្ងន់ទៅលើកំណើនសេដ្ឋកិច្ច ។ យោងតាមទស្សនៈស្តីពីការអភិវឌ្ឍន៍របស់ជនអន្តោប្រវេសន៍ បន្ថែមទៅលើភាពឈានមុខនៃសេដ្ឋកិច្ច ពួកគេអាចដាក់បញ្ចូលទិដ្ឋភាពសង្គម វប្បធម៌ បរិស្ថាន និងសហគមន៍ទៅក្នុងការអភិវឌ្ឍន៍ផងដែរ បានន័យថា ការអភិវឌ្ឍន៍គឺជាការផ្គុំគ្នារវាងការលូតលាស់សេដ្ឋកិច្ច និងការអភិវឌ្ឍន៍ផ្នែកសង្គម វប្បធម៌ និងសហគមន៍ ។ ជួនកាលជនអន្តោប្រវេសន៍យល់ឃើញថា គោលការណ៍ និងការខិតខំសំរាប់ការអភិវឌ្ឍន៍របស់ក្រុមជនភាគច្រើន ថាមិនសមស្រប និងគ្មាននិរន្តរភាព និងជាការរំលោភទន្ទ្រានចូលទៅក្នុងជីវភាពតាមបែបប្រពៃណីរបស់ពួកគេ ។ ការរំលោភទន្ទ្រានផ្នែករូបវ័ន្តនៃការអភិវឌ្ឍន៍ ទៅក្នុងតំបន់រស់នៅរបស់ជនអន្តោប្រវេសន៍ ក៏ដូចជាការរំលោភទន្ទ្រានផ្នែកសង្គមទៅក្នុងវប្បធម៌ជនអន្តោប្រវេសន៍ អាចត្រូវជនអន្តោប្រវេសន៍ និងអ្នកដទៃទៀតមើលឃើញថា ជាការរំលោភសិទ្ធិពោលគឺ សិទ្ធិមនុស្ស សិទ្ធិលើដីធ្លី និងសិទ្ធិប្រមូលផ្តុំគ្នាដើម្បីថែរក្សាវប្បធម៌ ។

## វប្បធម៌ និងការអភិវឌ្ឍន៍

បំណងរបស់ជនអន្តោប្រាម គឺកិច្ចការពារអត្តសញ្ញាណភាពវប្បធម៌របស់ពួកគេ និងរក្សានូវទិដ្ឋភាពទាំងឡាយនៃវប្បធម៌ ដែលមានមូលដ្ឋាននៅលើទឹកដីដូនតា និងធនធាន ហើយប្រការនេះកំពុងត្រូវបានគេទទួលស្គាល់កាន់តែច្រើន ក្នុងរង្វង់សហគមន៍អភិវឌ្ឍន៍អន្តរជាតិ ។ មានការទទួលស្គាល់កាន់តែច្រើនលើគោលការណ៍របស់ជនអន្តោប្រាមក្នុងការកំណត់នូវជំហាន និងគន្លងផ្លូវអភិវឌ្ឍរបស់ពួកគេផ្ទាល់ ហើយមានកំណើននៃការទទួលស្គាល់ថា ភាពចំរុះគ្នាខាងផ្នែកសង្គម និងវប្បធម៌ គឺជាផលប្រយោជន៍សង្គម តែមិនមែនជាឧបសគ្គសំរាប់ការអភិវឌ្ឍន៍ជាតិ ឬក៏ស្ថេរភាពសេដ្ឋកិច្ចនោះទេ ។ មានកំណើននៃការទទួលស្គាល់ថា នៅក្នុងគ្រប់វប្បធម៌ទាំងអស់សុទ្ធសឹងតែមានភាពថ្លៃថ្នូរ ហើយចាំបាច់ត្រូវធានាឱ្យមានឱកាសស្មើភាពសំរាប់ប្រជាជនគ្រប់ស្រទាប់នៅក្នុងសង្គម និងថាប្រជាជនគ្រប់ស្រទាប់ទាំងអស់នៃសង្គមត្រូវមានឱកាសចូលរួម និងទទួលបាននូវផលកំរៃពីការអភិវឌ្ឍន៍ស្មើៗគ្នា ។

# ច្បាប់ និងអនុសញ្ញានានាដែលពាក់ព័ន្ធដល់ជនអន្តោប្រាម

## ច្បាប់ជាតិ និងទំលាប់ប្រតិបត្តិ

ដោយសារតែជនអន្តោប្រាមមួយភាគធំនៃពិភពលោករស់នៅក្នុងទ្វីបអាស៊ី និងតំបន់ប៉ាស៊ីភិច ស្ទើរតែគ្រប់ប្រទេសក្នុងតំបន់ ADB មានប្រជាជនអន្តោប្រាមរស់នៅ ។ ថ្វីត្បិតតែប្រសិទ្ធិភាពនៃច្បាប់អាចមានភាពប្លែកៗពីគ្នាក៏ដោយ ក៏ប្រទេសមួយចំនួនទទួលស្គាល់ស្ថានភាពពិសេសរបស់ជនអន្តោប្រាម ហើយផ្តល់នូវបុព្វសិទ្ធិដល់ពួកគេ និងការពារពួកគេក្នុងនាមជាប្រជាពលរដ្ឋ ។ ប្រទេសមួយចំនួនតូចបានអនុវត្តច្បាប់ដែលទទួលស្គាល់នូវសិទ្ធិមួយចំនួនរបស់ជនអន្តោប្រាមទៅលើទឹកដីដូនតា ឬដែលគាំទ្រដល់ជនអន្តោប្រាមក្នុងការទទួលបានមកវិញ និងពង្រឹងស្ថាប័នសង្គម វប្បធម៌ និងច្បាប់ទម្លាប់របស់ពួកគេ ។ ក្នុងករណីជាច្រើន ការជំរុញឱ្យអនុវត្តច្បាប់នៅមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយទេ ។

ប្រទេសមួយចំនួន ធ្លាប់ឆ្លងកាត់នូវទំនាស់រវាងផលប្រយោជន៍ជនអន្តោប្រាម និងសហគមន៍ជនដែលមានឧត្តមភាពលើសលុប និងក្រុមជនជាតិភាគច្រើន ។ ទំនាស់ទាំងនេះជាញឹកញាប់ច្រើនទាក់ទងនឹងការត្រួតត្រាលើ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ នៅក្នុងតំបន់ជាប្រពៃណីរបស់ប្រជាជនអន្តោប្រាម ។ ជាញឹកញាប់ រដ្ឋាភិបាល ឬអ្នករកផលប្រយោជន៍ពីខាងក្រៅ ចាប់យកទឹកដីដូនតា ឬធនធាននានានៅក្នុងទឹកដីទាំងនោះ ដោយសំអាងលើហេតុផលនៃគំរូការផ្នែកអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ច ។ ចំនួនប្រជាជនអន្តោប្រាមតិចតួចនៅលើទឹកដីដ៏ធំទូលាយ និងការមិនប្រើប្រាស់ធនធានបែបអតិផលជារឿយៗ ត្រូវបានជនរកផលប្រយោជន៍ពីខាងក្រៅចាត់ទុកថា ជាអប្រសិទ្ធិភាពផ្នែកសេដ្ឋកិច្ច ឬជាការបាត់បង់ឱកាស ។ ជួនកាល ទំលាប់ប្រតិបត្តិក្នុងការគ្រប់គ្រងដីធ្លី និងធនធានរបស់ប្រជាជនអន្តោប្រាម ត្រូវបានគេចាត់ទុកថាមើលឃើញថាគ្មានចិរភាព និងបណ្តាលឱ្យមានការខូចខាតបរិស្ថាន ។

នៅក៏រិតជាតិ ក្នុងករណីខ្លះ ច្បាប់ គោលនយោបាយ និងវិធានការថ្មីៗដទៃទៀតអាច ជាការចាំបាច់ ក្នុងការសំរុះសំរួលតំរូវការប្រកបដោយភាពប្រណាំងប្រជែង និងទំនាស់ផល ប្រយោជន៍ ជាពិសេសប្រសិនបើចាំបាច់ត្រូវការពារផលប្រយោជន៍របស់ជនអន្តោប្រាម ។ ក៏ប៉ុន្តែ នៅក្នុងគ្រប់ករណី ADB ត្រូវតែគោរពឆន្ទៈរបស់រដ្ឋាភិបាល ដោយរួមបញ្ចូលទាំង ច្បាប់ និងគោលនយោបាយដែលមាន ព្រមទាំងសិទ្ធិរដ្ឋាភិបាលក្នុងដកហូតដីធ្លីឯកជនមក ប្រើជាប្រយោជន៍សាធារណៈ ដោយមានសំណងសមស្រប ។ ការជ្រើសរើសកម្មវិធីនានា និងគំរោងសំរាប់ប្រទេសនីមួយៗ ត្រូវធ្វើឡើងក្នុងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល ។ នៅពេលដែលជួបប្រទះនឹងការលំបាក ADB អាចនឹងផ្តល់ការណែនាំ និងជំនួយ តាមរយៈ យន្តការនានា ដូចជាការពិភាក្សាលើគោលនយោបាយ និងជំនួយបច្ចេកទេសជាដើម ។

## អនុសញ្ញា និងសេចក្តីថ្លែងការណ៍អន្តរជាតិ

សហាគមន៍អន្តរជាតិបានបង្ហាញពីការកើនឡើងនៃកង្វល់ ក្នុងកិច្ចការពារសិទ្ធិរបស់ជន អន្តោប្រាម ។ អនុសញ្ញា និងសេចក្តីប្រកាសនានារបស់សហាគមន៍អន្តរជាតិផ្តល់នូវក្របខ័ណ្ឌ ទូលំទូលាយមួយ ព្រមទាំងសេចក្តីថ្លែងការណ៍នានា ពាក់ព័ន្ធនឹងកិច្ចការពារជនអន្តោប្រាម និងផលប្រយោជន៍ វប្បធម៌ របៀបរស់នៅ ការរស់រានមានជីវិតនៃវប្បធម៌ និងការ អភិវឌ្ឍន៍របស់ពួកគេ ។ គួរកត់សំគាល់ផងដែរថា ប្រទេសមួយចំនួនធំនៃសហាគមន៍ អន្តរជាតិ ពុំទាន់បានផ្តល់សច្ចាប័នដល់ច្បាប់អន្តរជាតិមួយចំនួន ដែលទាក់ទងនឹងប្រជាជន អន្តោប្រាមនៅឡើយទេ ។

សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (ឆ្នាំ ១៩៤៨) និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ (ឆ្នាំ ១៩៦៦) មានសារៈ សំខាន់យ៉ាងជាពិសេសសំរាប់ជនអន្តោប្រាម ។ សេចក្តីថ្លែងការណ៍ជាសកលផ្តល់នូវបទដ្ឋាន រួមសំរាប់សិទ្ធិមនុស្សរបស់ជនគ្រប់រូប និងគ្រប់ជាតិសាសន៍ ហើយប្រកាសពីសារៈសំខាន់នៃ សិទ្ធិខាងប្រពៃណី នយោបាយ និងសិទ្ធិពលរដ្ឋ ព្រមទាំងសិទ្ធិជាមូលដ្ឋានផ្នែកសង្គម សេដ្ឋកិច្ច និងវប្បធម៌ ផងដែរ ។ កិច្ចព្រមព្រៀងនេះមានបញ្ជាក់អំពីសិទ្ធិពលរដ្ឋ និង

សិទ្ធិនយោបាយ ព្រមទាំងគោលការណ៍ណែនាំនានា ដោយផ្អែកលើសេចក្តីថ្លែងការណ៍ជាសកល ។

អនុសញ្ញាឆ្នាំ ១៩៥៧ លេខ ១០៧ របស់អង្គការពលកម្មអន្តរជាតិ (ILO) ស្តីពី *កិច្ចការពារ និងសមាហរណកម្មជនអន្តោប្រាម និងកុលសម្ព័ន្ធ និងប្រជាជនពាក់កណ្តាលកុលសម្ព័ន្ធ នៅក្នុងប្រទេសឯករាជ្យនានា* មានបញ្ជាក់ពីសិទ្ធិរបស់ជនអន្តោប្រាមក្នុងការលើកកំពស់ជីវភាពផ្នែកសំភារៈ និងការអភិវឌ្ឍន៍ផ្នែកស្មារតី ដែលជាច្បាប់អន្តរជាតិលើកទីមួយក្នុងការជួយគាំទ្រដោយចំពោះទៅដល់ជនអន្តោប្រាម ។ ដោយដារតែ អនុសញ្ញានេះមានទស្សនៈថា ជនអន្តោប្រាមគួរតែត្រូវធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមមនុស្សភាគច្រើន ជាទស្សនៈដែលជាបន្តបន្ទាប់មនុស្សភាគច្រើនយល់ថាមិនសមស្រប នៅឆ្នាំ ១៩៨៩ អង្គការ ILO បានចេញអនុសញ្ញាលេខ ១៦៩ ឈ្មោះ *អនុសញ្ញា ស្តីពីជនអន្តោប្រាម និងកុលសម្ព័ន្ធក្នុងប្រទេសឯករាជ្យនានា* ។

អនុសញ្ញាលេខ ១៦៩ បង្ហាញពីទស្សនៈគ្រឹះថា របៀបរបបរស់នៅនៃជនអន្តោប្រាម និងជនដែលរស់នៅជាកុលសម្ព័ន្ធ ត្រូវតែថែរក្សាឱ្យរស់រានមានជីវិតបន្តទៀត ក៏ដូចជាទស្សនៈដែលថា ជនអន្តោប្រាម និងជនដែលរស់នៅជាកុលសម្ព័ន្ធទាំងនោះ ព្រមទាំងស្ថាប័នប្រពៃណីរបស់ពួកគេ ត្រូវតែមានការទាក់ទិនយ៉ាងជិតស្និទ្ធជាមួយនឹងការធ្វើផែនការ និងការអនុវត្តន៍គំរោងអភិវឌ្ឍន៍នានា ដែលមានផលប៉ះពាល់ទៅលើក្រុមជនទាំងនោះ ។ ក្នុងនាមជាបរិធានច្បាប់អន្តរជាតិ ដែលមានភាពពេញលេញ និងថ្មីបំផុត ពាក់ព័ន្ធនឹងបញ្ហាជាអាយុជីវិតរបស់ជនអន្តោប្រាម និងជនកុលសម្ព័ន្ធ អនុសញ្ញាលេខ ១៦៩ បញ្ចូលមាត្រានានាដែលទាក់ទងនឹងការពិគ្រោះយោបល់ ការចូលរួម សន្តិសុខសង្គម សុខភាព ការអភិវឌ្ឍន៍ធនធានមនុស្ស និងបរិស្ថាន ។ មកទល់សព្វថ្ងៃនេះ មានប្រទេសមួយចំនួនតូចប៉ុណ្ណោះ ដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញាលេខ ១៦៩ ហើយក្នុងនោះ ពុំមានប្រទេសណាមួយសោះនៅក្នុងតំបន់អាស៊ីប៉ាស៊ីភិចនេះ ។

*របៀបវារៈទី ២១* ដែលត្រូវបានអនុម័តនៅក្នុងសន្និសីទអង្គការសហប្រជាជាតិ ក្នុងឆ្នាំ ១៩៩២ ស្តីអំពី បរិស្ថាន និងការអភិវឌ្ឍន៍ (UNCED) ទទួលស្គាល់បច្ចុប្បន្នភាព និងសក្តានុពលនៃការចូលរួមវិភាគទានរបស់ជនអន្តោប្រាម និងជនកុលសម្ព័ន្ធ នៅក្នុងការ

អភិវឌ្ឍន៍ប្រកបដោយចិរភាព ។ *អនុសញ្ញាស្តីពីជីវៈចម្រុះឆ្នាំ ១៩៩២* អំពាវនាវឱ្យភាគីជាសមាជិក គោរពចំណេះដឹងជាប្រពៃណីរបស់ជនអន្តោប្រាម ក្នុងកិច្ចការថែរក្សា និងការប្រើប្រាស់ជីវៈចំរុះប្រកបដោយនិរន្តរភាព ។ *សេចក្តីថ្លែងការណ៍ និងកម្មវិធីសកម្មភាពទីក្រុងវីយែន* ដែលកើតចេញពីសន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្សក្នុងឆ្នាំ ១៩៩៣ ទទួលស្គាល់សេចក្តីថ្លៃថ្នូរ និងវិភាគទានវប្បធម៌ឥតពីររបស់ជនអន្តោប្រាម ហើយធ្វើការបញ្ជាក់ដ៏មុតមាំជាថ្មីនូវការប្តេជ្ញារបស់សហគមន៍អន្តរជាតិ ដើម្បីសុខមាលភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌នៃជនអន្តោប្រាម ក៏ដូចជាការទទួលផលរបស់ពួកគេពីផ្លែផ្កានៃការអភិវឌ្ឍន៍ប្រកបដោយចិរភាព ។

*សេចក្តីព្រាងសេចក្តីថ្លែងការស្តីពីសិទ្ធិជនអន្តោប្រាម* ឆ្នាំ១៩៩៣ របស់អង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើង ក្រោមការចូលរួមដោយផ្ទាល់ពីតំណាងពួកជនអន្តោប្រាម ហើយបច្ចុប្បន្នកំពុងស្ថិតនៅក្រោមការពិចារណានៅអង្គការសហប្រជាជាតិ ។ សេចក្តីព្រាងសេចក្តីថ្លែងការនេះ ដោះស្រាយបញ្ហានានា ដូចជា សិទ្ធិក្នុងការចូលរួម សិទ្ធិជនអន្តោប្រាមក្នុងការដឹកនាំការអភិវឌ្ឍន៍របស់ពួកគេផ្ទាល់ សិទ្ធិរបស់ជនអន្តោប្រាមក្នុងការកំណត់ និងបង្កើតអាទិភាព និងយុទ្ធសាស្ត្រនានា សំរាប់ការអភិវឌ្ឍន៍ ឬការប្រើប្រាស់ដីធ្លីពី និងធនធានពីដូនតា ព្រមទាំងសិទ្ធិស្វ័យសំរេច ។ ការលេចឡើងនូវក្តីកង្វល់អំពីក្រុមជនអន្តោប្រាមបានជំរុញឱ្យអង្គការសហប្រជាជាតិធ្វើសេចក្តីប្រកាសចាត់ទុកឆ្នាំ ១៩៩៣ ថាជាឆ្នាំនៃជនអន្តោប្រាមពិភពលោក និងចាត់ទុកទសវត្សចាប់តាំងពីខែធ្នូ ឆ្នាំ ១៩៩៤ ថាជាទសវត្សនៃជនអន្តោប្រាម ។

# វត្ថុបំណងនៃគោលនយោបាយ ដំណើរការ និង ដំណោះស្រាយក្នុងរង្វង់ ADB

## វត្ថុបំណងនៃគោលនយោបាយ

ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ADB ប្រតិបត្តិតាមគោលនយោបាយមួយ និង យុទ្ធសាស្ត្រពាក់ព័ន្ធ ព្រមទាំងវិធីដោះស្រាយនានា ដែលទទួលស្គាល់នូវភាពងាយរងគ្រោះជាសក្តានុពលរបស់ជនអន្តោគ្រាមក្នុងដំណើរការអភិវឌ្ឍន៍ ហើយដែលធានាថា ជនអន្តោគ្រាមមានឱកាសនឹងចូលរួមក្នុងការអភិវឌ្ឍន៍ និងទទួលបានផលកំរៃពីការអភិវឌ្ឍន៍នេះ ប្រកបដោយសមភាព ។ យុទ្ធសាស្ត្រ និងវិធីដោះស្រាយរបស់ ADB គឺរៀបចំធ្វើឡើង ដើម្បីជៀសវាងផលប៉ះពាល់ជាអវិជ្ជមានលើជនអន្តោគ្រាម ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន និងដើម្បីផ្តល់នូវការទូទាត់ជាសំណងសមស្របដល់ពួកគេ នៅពេលដែលផលប៉ះពាល់កើតឡើងដោយជៀសមិនរួច ។ កិច្ចប្រឹងប្រែងក្នុងការអភិវឌ្ឍន៍របស់ ADB ធ្វើឡើងដើម្បីធានាថា គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ទាំងឡាយ ដែលមានឥទ្ធិពលដល់ជនអន្តោគ្រាម គឺជាគំនិតផ្តួចផ្តើមដែលមានប្រសិទ្ធភាព និងប្រកបដោយចិរភាព ។ គំនិតផ្តួចផ្តើមបែបនេះត្រូវតែស៊ីសង្វាក់គ្នា ទាំងផ្នែកខ្លឹមសារ និងរចនាសម្ព័ន្ធ ទៅនឹងវប្បធម៌ ស្ថាប័នសង្គម និងស្ថាប័នសេដ្ឋកិច្ចរបស់ក្រុមជនដែលរងប៉ះពាល់ ហើយសមស្របទៅនឹងតំរូវការ សេចក្តីប្រាថ្នា និងការទាមទាររបស់ក្រុមជនដែលរងការប៉ះពាល់ ។ គំនិតផ្តួចផ្តើមនានាគួរតែត្រូវទទួលការយល់ព្រមពីសហគមន៍ដែលរងការប៉ះពាល់ ដោយរួមបញ្ចូលទាំងការគោរពដល់សេចក្តីថ្លៃថ្នូរ សិទ្ធិមនុស្ស និងភាពគ្មានពីរនៃវប្បធម៌ជនអន្តោគ្រាមផង ។

យុទ្ធសាស្ត្រ និងវិធីដោះស្រាយនានាសំរាប់ការអភិវឌ្ឍន៍ ដែលមានផលប៉ះពាល់ទៅលើជនអន្តោគ្រាម ត្រូវតែរួមបញ្ចូលទាំងយន្តការច្បាស់លាស់ សំរាប់វិភាគស្ថានភាពពួកគេដោយសត្យានុម័ត និងត្រឹមត្រូវ ។ ដំណើរការអភិវឌ្ឍន៍ត្រូវតែរួមបញ្ចូលនូវតម្លាភាព និង

ភាពទទួលខុសត្រូវ ។ គោលនយោបាយចំពោះជនអន្តោគ្រាមត្រូវអនុវត្តសំរាប់កិច្ចប្រតិបត្តិការ ទាំងនៅក្នុងផ្នែកសាធារណៈ និងទាំងផ្នែកឯកជន ។

យុទ្ធសាស្ត្រ និងរបៀបដោះស្រាយទាក់ទងនឹងជនអន្តោគ្រាមដែល ADB យកមកប្រើប្រាស់ ត្រូវបានរៀបចំធ្វើឡើងនៅលើក្របខ័ណ្ឌយុទ្ធសាស្ត្រ និងបទពិសោធន៍អនុវត្តន៍ដែលមាន ។ គោលនយោបាយដែលធ្វើការដោះស្រាយបញ្ហាជនអន្តោគ្រាមបំពេញ និងគាំទ្រ ហើយក៏ត្រូវបានបំពេញ និងត្រូវបានគាំទ្រវិញ ដោយគោលនយោបាយដទៃទៀតរបស់ ADB ។ ការអនុវត្តន៍តាមគោលនយោបាយលើជនអន្តោគ្រាមពុំមានន័យថា គេពុំចាំបាច់ត្រូវអនុវត្តតាមគោលនយោបាយដទៃទៀតរបស់ ADB នោះឡើយ ។

## ដំណើរការកិច្ចប្រតិបត្តិការ

### ការវាយតំលៃបឋមផ្នែកសង្គម

ជំហានទីមួយក្នុងការដោះស្រាយកង្វល់របស់ជនអន្តោគ្រាម គឺធ្វើឡើងតាមរយៈការវាយតំលៃបឋមផ្នែកសង្គម (initial social assessment: ISA) ។ សំរាប់រាល់គំរោងការអភិវឌ្ឍន៍របស់ ADB នីមួយៗ ទាមទារឱ្យមានការវាយតំលៃបឋមផ្នែកសង្គមមួយ [2] ។ ការវាយតំលៃបឋមផ្នែកសង្គមកំណត់នូវអ្នកទទួលផលពីគំរោង ក៏ដូចជាក្រុមដែលទទួលផលប៉ះពាល់ជាអវិជ្ជមាន ។ ការវាយតំលៃបឋមផ្នែកសង្គមឆ្លើយតបទៅនឹងតំរូវការ ការទាមទារ និងសមត្ថភាពមនុស្ស ក៏ដូចជាវិស័យសង្គមកិច្ចសំខាន់ៗ ដែលគំរោងណាមួយត្រូវតែដោះស្រាយ ដូចជាការផ្លាស់ទីលំនៅដោយបង្ខំ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍មនុស្ស យេនឌ័រនិងការអភិវឌ្ឍន៍ និងក្រុមដែលងាយរងគ្រោះ ។ អាស្រ័យហេតុ

[2] ការពន្យល់ពិស្តារស្តីពីការវាយតំលៃបឋមផ្នែកសង្គម មាននៅក្នុង *សៀវភៅប្រតិបត្តិការរបស់ ADB* (ផ្នែក ៤៧) និង *សេចក្តីណែនាំសំរាប់ការដាក់បញ្ចូលវិស័យសង្គមកិច្ចក្នុងកិច្ចប្រតិបត្តិការរបស់ ADB* ។ ADB ទីក្រុងម៉ានីល ខែតុលា ១៩៩៣ ទំព័រ ២៣-២៦ ។ របៀបដោះស្រាយជាក់លាក់របស់ការវាយតំលៃបឋមផ្នែកសង្គម ដែលរួមបញ្ចូលទាំងតារាងត្រួតពិនិត្យតាមវិស័យនានាលើបញ្ហាដែលពាក់ព័ន្ធ មាននៅក្នុង *សៀវភៅសំរាប់ការដាក់បញ្ចូលវិស័យសង្គមកិច្ចក្នុងគំរោងការ*, ADB ទីក្រុងម៉ានីល ខែឧសភា ១៩៩៤ ។

នេះ បញ្ហាជនអន្តោប្រាមគឺជាបញ្ហាពិសេស ដែលត្រូវតែយកទៅពិចារណា នៅក្នុងដំណើរការវាយតំលៃបឋមផ្នែកសង្គម ។ ការវាយតំលៃបឋមផ្នែកសង្គមត្រូវតែធ្វើឱ្យបានឆាប់តាមដែលអាចធ្វើបាន នៅក្នុងដំណើរការនៃគំរោងអភិវឌ្ឍន៍ ជាពិសេសនៅមុនដំណាក់កាលសិក្សាស្ថានភាពជាក់ស្តែងនៃជំនួយបច្ចេកទេសរៀបចំគំរោង (project preparatory technical assistance: PPTA) ឬការសិក្សារៀបចំដទៃទៀត ដើម្បីធានាថា កង្វល់របស់សង្គមដែលពាក់ព័ន្ធ នឹងត្រូវបានយកទៅពិចារណា នៅក្នុងការរៀបចំគំរោង ។

ប្រសិនបើការវាយតំលៃបឋមផ្នែកសង្គមកំណត់ឃើញថា ជនអន្តោប្រាមអាចទទួលផលប៉ះពាល់យ៉ាងខ្លាំងដោយសារអន្តរាគមន៍ណាមួយរបស់ ADB ឬក៏ថា ជនអន្តោប្រាមមានភាពចាញ់ប្រៀប ឬងាយរងគ្រោះ នៅក្នុងអន្តរាគមន៍មួយ ដោយសារតែអត្តសញ្ញាណសង្គម និងវប្បធម៌របស់ពួកគេ នោះគេត្រូវតែបង្កើតឱ្យមានផែនការដោយឡែកមួយសំរាប់ជនអន្តោប្រាម ដើម្បីដោះស្រាយក្តីកង្វល់ពួកគេ ដោយមានកំណត់ពេលវេលា និងការផ្តល់ថវិកាសមស្រប ។ ផែនការនេះនឹងត្រូវដាក់បញ្ចូល ជាផ្នែកមួយមិនអាចខ្វះបាននៃការរៀបចំគំរោងការ ។

ការវាយតំលៃបឋមផ្នែកសង្គមនឹងដោះស្រាយបញ្ហានិយមន័យ និងអត្តសញ្ញាណកម្មរបស់ជនអន្តោប្រាម នៅក្នុងបរិបទជាក់លាក់នៃគំរោងណាមួយ ។ និយមន័យ និងអត្តសញ្ញាណកម្មបែបនេះគួរពិចារណាទៅលើគ្រប់កត្តាពាក់ព័ន្ធ រួមបញ្ចូលទាំងការពិចារណាលើលក្ខណៈពិសេសនៃប្រទេស ច្បាប់ និងគោលនយោបាយជាតិ ។ ផែនការលើជនអន្តោប្រាមគួរសំដៅជាពិសេសទៅលើជនអន្តោប្រាម ដែលនឹងទទួលរងការប៉ះពាល់ និងបញ្ហាសង្គមសេដ្ឋកិច្ចជាក់ស្តែងសំខាន់ៗ ។

## ផែនការអភិវឌ្ឍន៍ជនអន្តោប្រាម

សំរាប់គំរោងជាជំនួយរបស់ ADB ដែលមានផលប៉ះពាល់អវិជ្ជមាន និងធ្ងន់ធ្ងរ ទៅលើជនអន្តោប្រាម គេចាំបាច់ត្រូវរៀបចំផែនការជនអន្តោប្រាមមួយ ដែលអាចទទួលបានដោយ ADB ។ ក្រៅពីការដោះស្រាយលើបញ្ហាជនអន្តោប្រាម និងបញ្ហាសង្គមដែលពាក់ព័ន្ធ ផែនការជនអន្តោប្រាមត្រូវបញ្ចូលវិធានការ និងវិធីដោះស្រាយជាក់លាក់ ដើម្បីដោះស្រាយបញ្ហាដែលមានផលប៉ះពាល់ដល់ជនអន្តោប្រាម ។ គំរោងណាមួយដែលមាន

ផលប៉ះពាល់ជាអវិជ្ជមានដល់ជនអន្តោប្រាម ត្រូវតែទទួលការរៀបចំជាថ្មីឱ្យបានសមរម្យ ដើម្បីបន្ធូរបន្ថយនូវផលប៉ះពាល់ជាអវិជ្ជមាននោះ ឬក៏ដាក់បញ្ចូលនូវផែនការទូទាត់សង ដែលអាចទទួលយកបាន ។ ការផ្តល់សំណងមិនអាចយកទៅជំនួសកិច្ចខិតខំបញ្ចៀស ឬ បន្ធូរបន្ថយផលប៉ះពាល់អវិជ្ជមាន ដែលគំរោងនោះអាចមានឡើយ ។

ផែនការជនអន្តោប្រាមអាចបង្កើតជាមូលដ្ឋានមួយ សំរាប់ការអនុវត្តន៏គំរោង ត្រួតពិនិត្យ និងវាយតំលៃលើរបៀបដែលគំរោងដោះស្រាយបញ្ហាជនអន្តោប្រាម ។ បណ្តាសមាសធាតុ ឬខនានាដោយឡែករបស់ផែនការ ត្រូវតែបញ្ចូលនៅក្នុងការរៀបចំគំរោង ។ ផែនការនេះត្រូវតែពិចារណាលើបញ្ហានិរន្តរភាពរបស់គំរោងដែលស្នើឡើង ក៏ដូចជាបញ្ហាទាក់ទងនឹងការអនុវត្តន៏គំរោងផងដែរ ។ ឧបសម្ព័ន្ធដែលមានក្នុងសៀវភៅនេះផ្តល់នូវធាតុសំខាន់ៗ ដែលត្រូវយកមកពិចារណាក្នុងការបង្កើតផែនការបែបនេះ ។

ការទទួលខុសត្រូវលើការរៀបចំផែនការជនអន្តោប្រាម ដែលអាចទទួលយកបានដោយ ADB និងលើការអនុវត្តផែនការនេះ គឺជាបន្ទុករបស់រដ្ឋាភិបាល និងអ្នកឧបត្ថម្ភគំរោង ។ បុគ្គលិក ADB ដែលពាក់ព័ន្ធនៅក្នុងដំណើរការគំរោង ដែលមានផលប៉ះពាល់លើជនអន្តោប្រាម ត្រូវតែផ្តល់ពតិមានទៅរដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគំរោងនានា ស្តីពីគោលនយោបាយរបស់ ADB ទៅលើជនអន្តោប្រាម ។ រដ្ឋាភិបាល ឬផ្នែកឯកជនដែលឧបត្ថម្ភគំរោង ត្រូវតែដាក់ផែនការជនអន្តោប្រាមជូន ADB ជាមួយគ្នានឹងការសិក្សាបុរេលទ្ធភាពនៃគំរោង ។ ដោយសារការចំណាយទៅលើផែនការជនអន្តោប្រាមមួយអាចមានផលប៉ះពាល់ និងអាចជាផ្នែកមួយនៃចំណាយទូទៅទៅលើគំរោងណាមួយ ហើយដោយហេតុថា ការអនុវត្តន៏ផែនការជនអន្តោប្រាមអាចមានផលប៉ះពាល់លើកាលវិភាគនៃការអនុវត្តន៏គំរោងជាទូទៅ នោះការរៀបចំផែនការនេះត្រូវតែធ្វើឱ្យហើយមុនដំណាក់កាលវាយតំលៃលើគំរោង ។ ក្នុងករណីចាំបាច់ និងសមស្រប ADB នឹងគាំទ្រការខិតខំរបស់រដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគំរោងដទៃទៀត តាមរយៈ :

- ជំនួយការក្នុងការបង្កើត និងការអនុវត្តន៏ផែនការជនអន្តោប្រាម
- ជំនួយការក្នុងការបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ និងបទបញ្ញត្តិនានា ព្រមទាំងសកម្មភាពជាក់ស្តែងដទៃទៀត ដែលទាក់ទងទៅនឹងជនអន្តោប្រាម

- ការផ្ដល់ជំនួយបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាពទីភ្នាក់ងារទាំងឡាយ ដែលទទួលខុសត្រូវចំពោះជនអន្ដោប្រាម
- ការផ្ដល់ថវិកាលើការចំណាយសមស្រប ក្នុងការអនុវត្តន៍ផែនការជនអន្ដោប្រាម ប្រសិនបើមានសំណើសុំ ។ ចំពោះគំរោងការណាមួយ ផែនការជនអន្ដោប្រាមជាចាំបាច់ត្រូវតែធ្វើឱ្យហើយមុនការវាយតំលៃគំរោង ។

ផែនការជនអន្ដោប្រាមត្រូវមានសេចក្ដីសង្ខេបមួយ ហើយបញ្ហាសំខាន់ៗនានានៃសេចក្ដីសង្ខេបនេះ គួរតែដាក់បញ្ចូលទៅក្នុងសេចក្ដីព្រាងរបាយការណ៍ និងអនុសាសន៍របស់ប្រធាន ដើម្បីពិចារណានៅក្នុងការប្រជុំពិនិត្យរបស់អ្នកគ្រប់គ្រង ក៏ដូចជានៅក្នុងករណីនីមួយៗ ក្នុងអនុសាសន៍ចុងក្រោយរបស់ប្រធាន ដើម្បីដាក់ជូនក្រុមប្រឹក្សានាយកពិចារណា ។

## ដំណោះស្រាយប្រតិបត្តិការ

ក្នុងការខិតខំអភិវឌ្ឍ ដែលផ្ដល់ផលប៉ះពាល់ទៅលើជនអន្ដោប្រាម គឺជាការចាំបាច់ដែល ADB បញ្ចូលក្ដីកង្វល់ចំពោះជនអន្ដោប្រាម ទៅក្នុងគ្រប់ជំហាននៃការរៀបចំកម្មវិធី ការពិនិត្យគំរោង និងវដ្ដនៃការរៀបចំគោលនយោបាយ ។ ក្រៅពីការពិចារណាក្នុងក្របខ័ណ្ឌកម្មវិធី និងគំរោង ឧបសគ្គនានាផ្នែករចនាសម្ព័ន្ធអាចមានផលប៉ះពាល់ទៅលើការធ្វើឱ្យសំរេចនូវវត្ថុបំណងនៃគោលនយោបាយ ។ ឧបសគ្គបែបនេះអាចជាកង្វះខាតនៃ :

- ក្របខ័ណ្ឌច្បាប់សមស្របនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក
- សមត្ថភាពចាំបាច់ ឬស្ថាប័ន និងទីភ្នាក់ងារអភិវឌ្ឍន៍ពាក់ព័ន្ធ
- ចំណេះដឹងសត្យានុម័ត និងពត៌មានពិស្ដារស្ដីពីជនអន្ដោប្រាម និងស្ថានភាពរបស់ពួកគេ
- ការលើកបង្ហាញដោយត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធិភាពអំពីជនអន្ដោប្រាម ។

បន្ថែមលើការដោះស្រាយដោយផ្ទាល់ទៅលើតំរូវការរបស់ជនអន្ដោប្រាម គេគួរតែរាវរកយុទ្ធសាស្ដ្រដើម្បីយកជ័យជំនះលើឧបសគ្គផ្នែករចនាសម្ព័ន្ធទាំងនេះ ។ គេគួរតែកំណត់នូវរបៀបដោះស្រាយប្រកបដោយប្រសិទ្ធិភាព សំរាប់ការផ្សព្វផ្សាយពត៌មាន និងទំនាក់ទំនងជាមួយសហគមន៍ជនអន្ដោប្រាម ជាពិសេសនៅទីកន្លែងណាដែលរបៀបដោះស្រាយ

បែបធម្មតាក្នុងការផ្សព្វផ្សាយពតិមាន និងការទាក់ទងគ្មានប្រសិទ្ធិភាព ។ វាអាចជាការចាំបាច់ក្នុងការការផ្តល់ការយកចិត្តទុកដាក់ជាពិសេសទៅលើកិច្ចការនានា ដូចជាក្តីកង្វល់របស់ស្ត្រីភេទនៃជនអន្តោគ្រាមជាដើម ។

សមិទ្ធិផលដែលសំរេចបានក្នុងការអនុវត្តន៍គោលនយោបាយ ដែលដោះស្រាយក្តីកង្វល់របស់ជនអន្តោគ្រាម អាចបង្កើតជាមូលដ្ឋានសំរាប់ការពិចារណាលើការកែតំរូវដោយសមរម្យនៅក្នុងប្រព័ន្ធច្បាប់ និងស្ថាប័នរបស់ប្រទេសអ្នកខ្ចី ។ ក្នុងន័យនេះ បញ្ហាជនអន្តោគ្រាមគួរតែយកមកពិចារណានៅក្នុងការត្រួតពិនិត្យ និងវាយតំលៃសកម្មភាពគំរោង ហើយគួរតែមានការចូលរួមរបស់ជនអន្តោគ្រាមក្នុងដំណើរការត្រួតពិនិត្យ និងវាយតំលៃនេះ ។ មធ្យោបាយសំរាប់រៀបចំគោលនយោបាយអាចរួមមានការពិភាក្សាលើគោលនយោបាយ និងជំនួយបច្ចេកទេសសមស្របដទៃទៀត ។ ជាការល្អ ការបង្កើតយុទ្ធសាស្ត្រចាំបាច់ ត្រូវតែឈរលើការពិគ្រោះយោបល់រវាង ADB រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក អ្នកឧបត្ថម្ភគំរោងដែលពាក់ព័ន្ធ តំណាងជនអន្តោគ្រាម និងភាគីដទៃទៀត ។

បញ្ហាសំខាន់ដែលគួរយកមកពិចារណា នៅពេលដែល ADB ពិចារណាលើកិច្ចការជនអន្តោគ្រាម និរន្តរភាព និងការអភិវឌ្ឍន៍នៃសហគមន៍ជនអន្តោគ្រាម រួមមាន :

- ការទទួលស្គាល់តាមផ្លូវច្បាប់នូវទឹកដីដូនតា និងសិទ្ធិជាប្រពៃណីរបស់ជនអន្តោគ្រាមទៅលើទឹកដី និងធនធាននានា
- ការទទួលស្គាល់ភាពស្របច្បាប់នៃស្ថាប័នសង្គម និងច្បាប់របស់ជនអន្តោគ្រាម
- ការទទួលស្គាល់សិទ្ធិរបស់ជនអន្តោគ្រាមក្នុងការកំណត់ទិសដៅអភិវឌ្ឍន៍ និងការកែប្រែរបស់ពួកគេ ។

ក្នុងករណីចាំបាច់ និងសមស្រប ត្រូវផ្តល់ឱ្យនូវការគាំទ្រក្នុងការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពរបស់សហគមន៍ជនអន្តោគ្រាម ។ ដូចគ្នានេះដែរ នៅពេលដែលចាំបាច់ និងសមស្រប ត្រូវផ្តល់ការគាំទ្រក្នុងការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាព ចំពោះស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ នៅពេលដែលការគាំទ្របែបនេះអាចបង្កើននូវលទ្ធផល និងប្រសិទ្ធិភាពនៃស្ថាប័នទាំងនោះ ។

## ស្ថាប័នពាក់ព័ន្ធ

ការិយាល័យបរិស្ថាន និងអភិវឌ្ឍន៍សង្គម (Office of Environment and Social Development: OESD) ទទួលខុសត្រូវផ្នែកចាត់ចែងជាចំបង សំរាប់ការអនុវត្តគោលនយោបាយរបស់ ADB ស្តីពីជនអន្តោប្រាម ។ OESD ផ្តល់ការណែនាំ និងជំនួយដល់នាយកដ្ឋាន និងការិយាល័យដទៃទៀត ស្តីពីការអនុវត្តន៍គោលនយោបាយនៅក្នុងកិច្ចប្រតិបត្តិការរបស់ ADB ហើយធ្វើការពិគ្រោះយោបល់ជាមួយនាយកដ្ឋាន និងការិយាល័យទាំងនោះ ស្តីពីការរៀបចំទំលាប់ប្រតិបត្តិ និងនីតិវិធីពាក់ព័ន្ធនានា ។

OESD ទទួលខុសត្រូវចំពោះការបង្កើត និងសំរបសំរួលការណែនាំប្រតិបត្តិការសំរាប់អនុវត្ត និងធ្វើប្រតិបត្តិការកម្មគោលនយោបាយស្តីពីជនអន្តោប្រាម ។ ការណែនាំទាំងនេះធ្វើឡើងដោយមានការចូលរួមយោបល់ និងសហការដ៏សកម្មពីនាយកដ្ឋាន និងការិយាល័យដទៃទៀតរបស់ ADB ។ OESD តែងប្រមូល និងផ្សព្វផ្សាយពត៌មានដែលពាក់ព័ន្ធទៅដល់អង្គភាព ADB ដទៃទៀតជាប្រចាំ ។

OESD មានអ្នកឯកទេសខាងអភិវឌ្ឍសង្គមម្នាក់ជាអ្នកទទួលបន្ទុករួមក្នុង ADB ទាំងមូល ហើយមាននាទីជាអ្នកផ្តល់យោបល់ និងការណែនាំដោយឡែកទៅលើកិច្ចការដែលទាក់ទងនឹងជនអន្តោប្រាមក្នុងកិច្ចប្រតិបត្តិការរបស់ ADB ។ យោងតាមភាពចាំបាច់ OESD ទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍ និងការប្រតិបត្តិគោលនយោបាយស្តីពីជនអន្តោប្រាម ។

*នាយកដ្ឋានកម្មវិធី* ទទួលខុសត្រូវលើការអនុវត្តន៍គោលនយោបាយស្តីពីជនអន្តោប្រាមដែលមានការពាក់ព័ន្ធទៅនឹងការរៀបចំកម្មវិធីរបស់ប្រទេស ព្រមទាំងទទួលខុសត្រូវលើការដាក់បញ្ចូលគោលនយោបាយទៅក្នុងការរៀបចំយុទ្ធសាស្ត្រប្រទេស និងទៅក្នុងការធ្វើអត្តសញ្ញាណកម្មគំរោង និងជំនួយការបច្ចេកទេស ។ ដំណើរការនេះត្រូវតែជាផ្នែកមួយនៃការពិភាក្សាគោលនយោបាយជាមួយរដ្ឋាភិបាល ។ ដោយសារតែដំនើរការធ្វើកម្មវិធីថ្នាក់

ជាតិ (ដោយរួមទាំងដំណើរការពាក់ព័ន្ធនឹងការរៀបចំយុទ្ធសាស្ត្រប្រតិបត្តិការរបស់ប្រទេសផង) គឺជាជំហានដំបូងក្នុងការធ្វើអត្តសញ្ញាណកម្មគំរោងការថ្នាក់ជាតិ នោះបញ្ហាជនអន្តោប្រាម នឹងមានសារៈសំខាន់នៅក្នុងដំណើរការនេះ ។ នាយកដ្ឋានកម្មវិធីពិចារណាបញ្ហាអភិវឌ្ឍសង្គម នៅពេលដែលវាលេចឡើងនៅក្នុងដំណើរការរៀបចំកម្មវិធីរបស់ប្រទេស និងនៅក្នុងការងារសេដ្ឋកិច្ច និងការងារតាមវិស័យ ។ *បេសកកម្មប្រចាំប្រទេស* ជាចំណុចសំរាប់ទាក់ទងថ្នាក់ជាតិ ផ្នែកបញ្ហាដែលទាក់ទងទៅនឹងជនអន្តោប្រាម និងជាអ្នកផ្តល់យោបល់ទៅបុគ្គលិកនៅទីស្នាក់ការធំ ។ ទីស្នាក់ការធំផ្តល់ការគាំទ្រចាំបាច់ក្នុងកិច្ចការនេះ ។

*នាយកដ្ឋានគំរោង* ទទួលខុសត្រូវលើទិដ្ឋភាពជាក់ស្តែងនៃគំរោងរបស់គោលនយោបាយជនអន្តោប្រាម ដោយរួមបញ្ចូលទាំងការផ្តល់ពត៌មានស្តីពីឧបញ្ញត្តិនៃគោលនយោបាយ និងការទាមទាររបស់ ADB ជូនរដ្ឋាភិបាល ស្ថាប័នប្រតិបត្តិគំរោង និងអ្នកឧបត្ថម្ភគំរោងដទៃទៀត ។

*ការិយាល័យប្រតិបត្តិតំបន់ប៉ាស៊ីភិច* ទទួលខុសត្រូវលើគោលនយោបាយជនអន្តោប្រាមពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក ADB ក្នុងតំបន់ប៉ាស៊ីភិច ។

*ការិយាល័យវាយតំលៃប្រតិបត្តិការ* តាមរយៈមុខងារវាយតំលៃជាក្រោយរបស់ខ្លួនទទួលភារកិច្ចធ្វើការវាយតំលៃលើប្រសិទ្ធិភាពនៃកិច្ចប្រតិបត្តិការ ADB ក្នុងការអនុវត្តន៍ និងប្រតិបត្តិគោលនយោបាយស្តីពីជនអន្តោប្រាម និងក្នុងការបង្កើតលក្ខណៈវិនិច្ឆ័យសំរាប់វាយតំលៃឱ្យបានសមស្រប ។

# គោលនយោបាយស្តីពីជនអន្តោប្រាណ

## គោលនយោបាយស្តីពីជនអន្តោប្រាណក្នុងកិច្ចប្រតិបត្តិការ ADB

សំរាប់អន្តរាគមន៍អភិវឌ្ឍដែលខ្លួនគាំទ្រ ឬផ្តល់ជំនួយ ADB នឹងធានាថា ប្រជាជន និងបុគ្គលដែលរងការប៉ះពាល់ យ៉ាងហោចណាស់នឹងបានរស់នៅ ដូចនៅពេលដែលគ្មានអន្តរាគមន៍ ឬបានទទួលនូវការទូទាត់ដោយសមស្រប និងគ្រប់គ្រាន់ ។ គោលនយោបាយនេះធានានូវឱកាសស្មើគ្នាសំរាប់ជនអន្តោប្រាណ ។ គោលនយោបាយនេះធានាថា បណ្តាអន្តរាគមន៍របស់ ADB ដែលមានផលប៉ះពាល់ទៅលើជនអន្តោប្រាណ អាច :

- ស្របទៅនឹងតំរូវការ និងសេចក្តីប្រាថ្នារបស់ជនអន្តោប្រាណដែលទទួលរងផលប៉ះពាល់
- ទាំងខ្លឹមសារ ទាំងរចនាសម្ព័ន្ធ ត្រូវគ្នាទៅនឹងស្ថាប័នវប្បធម៌ សង្គម និងសេដ្ឋកិច្ចរបស់ជនអន្តោប្រាណ
- ផ្តួចផ្តើម ធ្វើផែនការ និងអនុវត្ត ដោយមានការចូលរួមរបស់សហគមន៍ដែលរងផលប៉ះពាល់ ដោយផ្តល់ពត៌មានគ្រប់គ្រាន់
- ប្រកបដោយសមភាព ផ្នែកកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ និងផលនៃការអភិវឌ្ឍន៍នេះ
- មិនបង្ខំឱ្យទទួលយកនូវផលប៉ះពាល់ជាអវិជ្ជមាននៃការអភិវឌ្ឍន៍ ទៅលើជនអន្តោ-ប្រាណ ដោយគ្មានការទូទាត់សំណងសមរម្យ និងអាចទទួលបានឡើយ ។

ជាមួយនឹងទំលាប់ប្រតិបត្តិទាំងឡាយសំរាប់ឆ្លើយតបនឹងបញ្ហាជនអន្តោប្រាណ គោលនយោបាយនេះអនុវត្តឡើង ដោយស្របជាមួយ តែមិនដាក់ជំនួស ឬក៏ទាត់ចោលគោលនយោបាយ និងទំលាប់ប្រតិបត្តិដទៃទៀតរបស់ ADB ឡើយ ។ ធាតុនីមួយៗនៃគោលនយោបាយ និងទំលាប់ប្រតិបត្តិ ដែលដោះស្រាយបញ្ហាជនអន្តោប្រាណ ត្រូវបានយកទៅពិចារណាក្នុងបរិបទនៃគោលនយោបាយ និងវិធីអភិវឌ្ឍន៍របស់ជាតិ ហើយទំនាក់ទំនងគ្រឹះរវាង ADB និងរដ្ឋាភិបាល នៅតែជាមូលដ្ឋានសំរាប់ប្រតិបត្តិការនៅក្នុងប្រទេសណាមួយ

ជាក់លាក់ ។ គោលនយោបាយស្តីពីជនអន្តោប្រាមធានាថា ដំណើរវាយតំលៃបឋមផ្នែកសង្គម ដែលជាការងារចាំបាច់នៅក្នុងកិច្ចប្រតិបត្តិការរបស់ ADB ដាក់បញ្ចូលការពិចារណាជាក់លាក់ស្តីពីជនអន្តោប្រាម ថាជាប្រជាជនដែលអាចរងផលប៉ះពាល់ ។ ប្រសិនបើការវាយតំលៃបឋមផ្នែកសង្គមកំណត់ឃើញថា ជនអន្តោប្រាមនឹងជាប្រជាជនដែលទទួលផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរជាពិសេស ឬជាក្រុមដែលងាយរងគ្រោះដោយសារតែផលប៉ះពាល់បែបនេះ នោះរដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគំរោងដទៃទៀតចាំបាច់ត្រូវតែរៀបចំផែនការជនអន្តោប្រាម ដែលអាចទទួលបានដោយ ADB ។

ADB នឹងធ្វើការងារ ដើម្បីកសាងសមត្ថភាពផ្ទៃក្នុង ដែលសមស្រប និងចាំបាច់សំរាប់ឆ្លើយតបទៅនឹងបញ្ហាជនអន្តោប្រាម នៅក្នុងសកម្មភាពប្រតិបត្តិការរបស់ខ្លួន ។

ក្នុងករណីចាំបាច់ និងសមស្រប ADB នឹងធ្វើការជាមួយប្រទេសអ្នកខ្ចីជាសមាជិក សំដៅគាំទ្រ និងជួយដល់ការអភិវឌ្ឍន៍សមត្ថភាព ដើម្បីដោះស្រាយបញ្ហាជនអន្តោប្រាម ។ ប្រសិនបើចាំបាច់ និងសមស្រប ADB នឹងផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាពស្ថាប័នដោយឡែក ជូនដល់សហគមន៍ជនអន្តោប្រាម និងរដ្ឋាភិបាល ឱ្យសមស្របទៅនឹងគោលនយោបាយ និងរបៀបដោះស្រាយរបស់ ADB ដែលឆ្លើយតបទៅនឹងការអភិវឌ្ឍន៍ស្ថាប័ន និងការកសាងសមត្ថភាព ។

# ឧបសម្ព័ន្ធ

## ធាតុសំខាន់នានាក្នុងផែនការអភិវឌ្ឍជនអន្តោគ្រាម

1. ការទទួលខុសត្រូវលើការរៀបចំផែនការជនអន្តោគ្រាម ដែល ADB អាចទទួលយកបាន គឺជាបន្ទុករបស់រដ្ឋាភិបាល និងអ្នកឧបត្ថម្ភគំរោងដែលមានការពាក់ព័ន្ធ ។ ADB នឹងគាំទ្រកិច្ចខិតខំប្រឹងប្រែងនានារបស់រដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគំរោង នៅពេលណាចាំបាច់ និងសមស្រប ។ ធាតុសំខាន់ៗសំរាប់ធានាឱ្យផែនការអភិវឌ្ឍន៍ជនអន្តោគ្រាមមួយត្រូវរៀបចំឡើងដោយសមស្រប រួមមាន :

(i) ការរៀបចំផែនការអភិវឌ្ឍន៍មួយ ដែលគិតគូរយ៉ាងពេញលេញពីគោលបំណង និងជំរើសពេញចិត្តជាងគេរបស់ជនអន្តោគ្រាម ដែលទទួលរងផលប៉ះពាល់ពីគំរោង នៅក្នុងដំណាក់កាលរៀបចំគំរោង ។

(ii) ការសិក្សា ដើម្បីធ្វើអត្តសញ្ញាណកម្មរកផលប៉ះពាល់ជាអវិជ្ជមាន ដែលអាចកើតមានទៅលើជនអន្តោគ្រាមបណ្តាលមកពីគំរោង និងដើម្បីកំណត់នូវបណ្តាវិធានការទាំងឡាយ សំដៅបញ្ចៀស បន្ធូរបន្ថយ ឬទូទាត់ជាសំណង សំរាប់ផលប៉ះពាល់អវិជ្ជមានទាំងនេះ ។

(iii) វិធានការទាំងឡាយដើម្បីធានាឱ្យមានសមត្ថភាព ឬការពង្រឹងជំនាញផ្នែកសង្គម ច្បាប់ និងបច្ចេកទេស ដល់ស្ថាប័នរដ្ឋាភិបាល ដែលទទួលខុសត្រូវដោះស្រាយបញ្ហាជនអន្តោគ្រាម នៅក្រោមគំរោង ។

(iv) ការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធដែលមាន ដូចជាអង្គការក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានជំនាញក្នុងបញ្ហាទាក់ទងនឹងជនអន្តោគ្រាម ។

(v) ការពិចារណាលើរបៀបរបបចាត់ចែងសង្គម ជំនឿវប្បធម៌ និងការប្រើប្រាស់ទឹកដី និងធនធានពីដូនតា ក្នុងដំណាក់កាលរៀបចំគំរោង ។

(vi) ការគាំទ្រប្រព័ន្ធផលិតកម្មដែលអាចរស់រានបាន និងប្រកបដោយចិរភាព ដែលសំរបទៅនឹងតំរូវការ និងបរិស្ថាននៅនឹងមូលដ្ឋាន និងទៅតាមស្ថានភាពនៃជនអន្តោប្រាម ។

(vii) ការចៀសវាងការបង្កើត និងបន្ថែមការពឹងពាក់អាស្រ័យរបស់ជនអន្តោប្រាមទៅលើអង្គភាពគំរោង ដោយដាក់ជំនួសវិញនូវការលើកកំពស់ការជឿជាក់លើខ្លួនឯងនៃជនទាំងនោះ ។

(viii) ការកសាងសមត្ថភាពសហគមន៍ជនអន្តោប្រាម និងស្ថាប័ននានា ដើម្បីសំរួល និងគាំទ្រការចូលរួមប្រកបដោយប្រសិទ្ធិភាពក្នុងដំណើរការអភិវឌ្ឍន៍ ។

(ix) ពេលវេលាគ្រប់គ្រាន់ និងការចាត់ចែងសមស្រប សំរាប់ការងារដែលត្រូវធ្វើជាបន្ត ជាពិសេសក្នុងការដោះស្រាយបញ្ហាជនអន្តោប្រាមនៅក្នុងតំបន់ដាច់ស្រយាល ឬតំបន់ដែលគេមិនបានគិតគូរដល់ ដែលមានការពិសោធន៍ពីមុនតិចតួច ។

ការពិគ្រោះយោបល់ជាមួយក្រុមជនអន្តោប្រាម គឺជាគន្លឹះសំរាប់ការបង្កើតផែនការមួយប្រកបដោយប្រសិទ្ធិភាព ម៉ត់ចត់ និងឆ្លើយតបទៅនឹងការអភិវឌ្ឍន៍ជនអន្តោប្រាម ។

2. ជារឿយៗ ជនអន្តោប្រាមច្រើនតែខ្វះខាតពតិមាន ចំណេះដឹង សមត្ថភាពវិភាគ សមត្ថភាពចាត់ចែង ព្រមទាំងខ្វះខ្សែនយោបាយ និងអំណាច ក្នុងការដាក់ឥទ្ធិពល និងតំរង់ទិសដំណើរការអភិវឌ្ឍន៍ ដែលផ្តល់ផលប៉ះពាល់ដោយចំពោះ ឬប្រយោលទៅលើការរស់នៅរបស់ពួកគេ ។ គោលការណ៍មូលដ្ឋានដូចតទៅនេះ ត្រូវតែយកទៅអនុវត្ត សំរាប់គំរោងដែលគាំទ្រដោយ ADB ណា ដែលមានផលប៉ះពាល់ទៅលើជនអន្តោប្រាម :

(i) គ្រប់ផែនការអភិវឌ្ឍសំរាប់ជនអន្តោប្រាម ដោយរួមទាំងការផ្តល់នូវវិធានការសំរាប់កាត់បន្ថយនានាផង ត្រូវតែឈរលើការគិតគូរដ៏ពេញលេញដល់ជំរើស និងរបៀបដោះស្រាយ រួមទាំងការទាមទារឱ្យមានការពិគ្រោះយោបល់ ដែលឆ្លើយតបទៅនឹងប្រយោជន៍របស់បុគ្គល និងសហគមន៍ ដែលរងការប៉ះពាល់ដោយសារគំរោងនានា ។ អ្នកឯកទេសដែលមានជំនាញគ្រប់គ្រាន់ ត្រូវចូលរួមក្នុងការបង្កើតផែនការបែបនេះ និងដាក់ចុះនូវវិធានការកាត់បន្ថយនានា

ដោយធ្វើការពិគ្រោះយោបល់ជាមួយប្រជាជនទាំងប្រុស ទាំងស្រី ដែលទទួលរងផលប៉ះពាល់ ។ ការរៀបចំរបៀបដោះស្រាយ ផែនការ និងវិធានការកាត់បន្ថយនានា ត្រូវតែរួមបញ្ចូលការពិគ្រោះយោបល់ ជាមួយនឹងក្រុមជនដែលទទួលរងផលប៉ះពាល់ផងដែរ ។

(ii) នៅពេលដែលមានការបង្ហាញឱ្យឃើញថា គំរោងណាមួយអាចនឹងផ្តល់ផលប៉ះពាល់អវិជ្ជមានដល់ជនអន្តោគ្រាម ជាការចាំបាច់ដែលថា ទំហំ និងឥទ្ធិពលរបស់ផលប៉ះពាល់អវិជ្ជមាននេះ ត្រូវទទួលការវាយតំលៃដោយអ្នកឯកទេស ឬទីភ្នាក់ងារជំនាញនានា ហើយវិធានការកាត់បន្ថយសមស្របត្រូវបានគេធ្វើអត្តសញ្ញាណកម្ម នៅក្នុងការសិក្សាលទ្ធភាព ។ ជាការប្រសើរ ប្រសិនបើឥទ្ធិពលសរុបរបស់គំរោងណាមួយនឹងមិនត្រឹមតែភាពវិជ្ជមានប៉ុណ្ណោះទេ តែក៏ត្រូវឱ្យជនអន្តោគ្រាមយល់ថាមានភាពវិជ្ជមានដូចគ្នាផងដែរ ។ ប្រសិនបើបុគ្គល ឬសហគមន៍ត្រូវបាត់បង់ប្រព័ន្ធគាំទ្រផ្នែកសង្គមរបស់ខ្លួន ឬក៏របៀបរស់នៅរបស់ពួកគេ ដោយសារតែដំណើរការគំរោង ពួកគេត្រូវតែទទួលការទូរទាត់ជាសំណងយ៉ាងសមរម្យ ។

(iii) ការរៀបចំគំរោងត្រូវតែគិតគូរទៅដល់បរិបទសង្គម និងវប្បធម៌របស់ជនដែលរងផលប៉ះពាល់ ព្រមទាំងបំណិនប្រសព្វ និងចំណេះដឹងពួកគេ ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានក្នុងមូលដ្ឋាន ។ ការរៀបចំគំរោងត្រូវតែបញ្ជាក់លើភាពខ្លាំងរបស់ស្ថាប័នជនអន្តោគ្រាម និងសហគមន៍ ក៏ដូចជាស្ថាប័នសង្គមប្រពៃណី និងពុទ្ធិរបស់ជនអន្តោគ្រាម ហើយបើអាចធ្វើទៅបាន គួរតែចៀសវាងការបញ្ចូលការផ្លាស់ប្តូរណាមួយ ដែលមានលក្ខណៈមិនជាទីពេញចិត្ត និងមិនអាចទទួលបាន ទៅក្នុងផ្លូវជីវិតសហគមន៍ជនអន្តោគ្រាម ។

(iv) ក្នុងរយៈពេលរៀបចំគំរោង អ្នករៀបចំគំរោងត្រូវជំរុញការបង្កើត ឬពង្រឹងស្ថាប័ននានារបស់ជនអន្តោគ្រាម និងសហគមន៍ ដើម្បីសំរួលការចូលរួមពួកគេក្នុងការធ្វើអត្តសញ្ញាណកម្ម ធ្វើផែនការ អនុវត្ត និងវាយតំលៃគំរោង ។

យោងទៅតាមភាពចាំបាច់ ត្រូវផ្តល់នូវការបណ្តុះបណ្តាលដល់ជនអន្តោប្រវេសន៍ក្នុងការគ្រប់គ្រងសកម្មភាពគំរោង ។

(v) នៅកន្លែងណាដែលពុំមានបទពិសោធន៍ និងចំណេះដឹងក្នុងការបំពេញការងារឱ្យបានជោគជ័យជាមួយជនអន្តោប្រវេសន៍ពីមុនមក គេត្រូវតែអនុវត្ត និងវាយតំលៃលើប្រតិបត្តិការពិសោធន៍ជាមុនសិន មុននឹងចាប់ផ្តើមអនុវត្តគំរោងពេញលេញ ។

(vi) ប្រសិនបើស្ថាប័នរដ្ឋាភិបាល ដែលទទួលខុសត្រូវក្នុងការទាក់ទងជាមួយជនអន្តោប្រវេសន៍ មិនមានសមត្ថភាពផ្នែកច្បាប់ សង្គម និងបច្ចេកទេសចាំបាច់ ឬក៏ប្រសិនបើទំនាក់ទំនងរបស់ស្ថាប័នទាំងនោះ ជាមួយនឹងជនអន្តោប្រវេសន៍នៅខ្សោយ នោះចាំបាច់ត្រូវកំនត់រកអង្គការសហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបទពិសោធន៍នានា ដើម្បីឱ្យចូលរួមជាអន្តរការីក្នុងករណីដែលភាគីពាក់ព័ន្ធទាំងអស់ រួមទាំងរដ្ឋាភិបាលផង អាចទទួលយកបាន ។ គួរផ្តល់អាទិភាពទៅឱ្យតំណាងស្ថាប័នប្រពៃណីនានា ។ ចាំបាច់ត្រូវស្វែងរកវិធីកសាងសមត្ថភាពស្ថាប័នរដ្ឋាភិបាលនានា ។

(vii) ការអនុម័តរបស់ ADB ចំពោះគំរោងណាមួយ មិនត្រូវផ្អែកតែទៅលើគោលគំនិត និងគុណភាពរបស់ការរៀបចំគំរោងនោះទេ ប៉ុន្តែក៏ត្រូវផ្អែកលើទិសដៅ សមត្ថភាព និងប្រវត្តិប្រតិបត្តិការរបស់ភ្នាក់ងាររដ្ឋាភិបាល និងអ្នកឧបត្ថម្ភគំរោងដទៃទៀត ដែលទាក់ទិននឹងការអនុវត្តន៍គំរោងផងដែរ ។